ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃសុក្រ ៦រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២១

សេចក្តីប្រកាសព័ត៌មាន
ស្តីពីសិក្ខាសាលាពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ

នាថ្ងៃព្រហស្បតិ៍ ៥រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើ “សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ” ដែលបានប្រព្រឹត្តទៅតាមអនឡាញ (កម្មវិធី Zoom) ស្របតាមវិធានការ សុខាភិបាល ៣កុំ-៣ការពារ របស់រាជរដ្ឋាភិបាល និងបានដំណើរការរយៈពេលពេញមួយព្រឹក ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិតសភាចារ្យ ជួ វិជិត្ត រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ដោយមានវត្តមានចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញ តំណាងពីក្រសួង-ស្ថាប័នរដ្ឋ រាជធានី-ខេត្ត ក្រុង គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ និងអង្គការសាធារណៈប្រហាក់ប្រហែល សរុបប្រមាណជាង ៤០០នាក់។

អង្គសិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបង្ហាញពីវឌ្ឍភាពនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសាពើពន្ធ និងដាក់សេចក្តីព្រាងច្បាប់នេះទៅក្នុងកិច្ចពិភាក្សា ប្រមូលមតិ និងធាតុចូលសំខាន់ៗ ពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាតំណាងមកពីក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ សម្រាប់ជាមូលដ្ឋានពិនិត្យ ពិចារណា កែសម្រួល និង/ឬបន្ថែមខ្លឹមសារសំខាន់ៗ ទៅក្នុងសេចក្តីព្រាងច្បាប់នេះ ឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយ និងពេញលេញ ដើម្បីធានាប្រសិទ្ធភាព និងសក្តិសិទ្ធភាពក្នុងការគ្រប់គ្រង និងការប្រមូលចំណូលមិនមែនសារពើពន្ធ ឱ្យអស់សក្តានុពល។

ថ្លែងក្នុងឱកាសបើកអង្គសិក្ខាសាលាពិគ្រោះយោបល់នេះ **ឯកឧត្តមបណ្ឌិតសភាចារ្យ ជួ វិជិត្ត រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** បានលើកឡើងអំពីសមិទ្ធផលសំខាន់ៗធំៗជាច្រើនរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏វៃឈ្លាស និងប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មានដូចជា ការរក្សាបានពេញលេញនូវសុខសន្តិភាព បូរណភាពទឹកដី ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលជាកក្តាចម្បងដើម្បីសម្រេចបាននូវជវភាពនៃការកែទម្រង់ស៊ីជម្រៅ និងមុតស្រួចរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះមានដូចជា ការកែទម្រង់រដ្ឋបាលសាធារណៈ, ហិរញ្ញវត្ថុសាធារណៈ, ច្បាប់និងប្រព័ន្ធយុត្តិធម៌ និងការកែទម្រង់តាមបែបប្រជាធិបតេយ្យ

ថ្នាក់ក្រោមជាតិ ដោយអនុលោមតាម“**យុទ្ធសាស្ត្រចតុកោណ**” ទាំង ៣ដំណាក់កាល និងកំពុងបន្តអនុវត្ត“**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤**” ដែលបានធ្វើឱ្យកម្ពុជាផ្លាស់ប្តូរនូវរចនាសម្ព័ន្ធសេដ្ឋកិច្ច, លើកកម្ពស់ជីវភាពប្រជាជនទាំងផ្នែកសម្ភារៈ និងស្មារតី តាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព, បង្កើនការងារជូនប្រជាជន, ធានាសមធម៌សង្គម និងពង្រឹងប្រសិទ្ធភាពនៃអភិបាលកិច្ចរបស់ស្ថាប័នរដ្ឋ។

ជាមួយនេះ ក្នុងគោលដៅបង្កើនវឌ្ឍនភាពជាវិជ្ជមាន, បន្តចលនាអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាព និងភាពជាម្ចាស់ក្នុងការអភិវឌ្ឍប្រទេសរបស់ខ្លួន រាជរដ្ឋាភិបាលបានខិតខំរិះរកមធ្យោបាយ និងយុទ្ធសាស្ត្រប្រកដោយឆន្ទះមោះមុត ដើម្បីកៀរគរប្រមូលចំណូលឱ្យអស់លទ្ធភាព និងអស់សក្តានុពល សម្រាប់ទ្រទ្រង់ និងឆ្លើយតបទៅនឹងតម្រូវការនៃកំណើនចំណាយ តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រកៀរគរចំណូល២០១៩-២០២៣ បន្តពីយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម២០១៤-២០១៨។

តាមរយៈការអនុវត្តយុទ្ធសាស្ត្រកៀគរចំណូលរយៈពេលមធ្យម២០១៤-២០១៨ រយៈពេល ៥ឆ្នាំកន្លងមក ចំណូលចរន្តសរុបមានការកើនឡើងជាលំដាប់ពី **១៥,១% នៃផ.ស.ស** នៅឆ្នាំ២០១៣ ដល់ **២២,0% នៃផ.ស.ស** នៅឆ្នាំ២០១៨ ហើយមានកំណើនជាមធ្យមប្រមាណ **១,៤ ពិន្ទុភាគរយ នៃផ.ស.ស** ក្នុងមួយឆ្នាំ។ អំឡុងពេលបន្តការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ២០១៩-២០២៣, នៅឆ្នាំ២០១៩ សេដ្ឋកិច្ចកម្ពុជានៅបន្តរក្សាបាននូវកំណើនរឹងមាំក្នុងរង្វង់ **៧,១%** ដែលចំណូលចរន្តសរុបសម្រេចបាន **២៥,០៨ % នៃផ.ស.ស** ស្មើនឹង **១៣០,៥%** នៃច្បាប់ហិរញ្ញវត្ថុ។ ដោយឡែក ក្នុងឆ្នាំ២០២០ ដោយសារតែបរិការណ៍នៃការរីករាលដំងឺឆ្លងសកលបានចូលមកដល់ប្រទេសកម្ពុជា បានបណ្តាលឱ្យវិស័យជំរុញកំណើនសំខាន់ៗទទួលរងផលប៉ះពាល់គួរឱ្យកត់សម្គាល់ និងនាំឱ្យសេដ្ឋកិច្ចកម្ពុជាមានកំណើនអវិជ្ជមាន **៣,១%** ដោយសារវិបត្តិជំងឺកូវីដ-១៩នេះ ដែលចំណូលចរន្តឆ្នាំ២០២០ អនុវត្តបានត្រឹមតែចំនួន **២១,៦៤% នៃ ផ.ស.ស.** គឺទាបជាងច្បាប់ហិរញ្ញវត្ថុ **១០,៣%**។

ចំពោះចំណូលមិនមែនសារពើពន្ធ, នៅមុនស្ថានការណ៍នៃការរីករាលជំងឺកូវីដ-១៩, សម្រេចបានជាមធ្យមប្រមាណ **២%** នៃផ.ស.ស និងបានរួមចំណែកប្រមាណ **១៤%** នៃចំណូលចរន្តសរុប។ ជាក់ស្តែង នៅក្នុងឆ្នាំ២០១៩ ចំណូលមិនមែនសារពើពន្ធសម្រេចបានប្រមាណ **៣ ៣៤២ ប៊ីលានរៀល (ឬប្រមាណ ៨២៥ លានដុល្លារអាមេរិក)** ត្រូវជា **៣,០៤%នៃ ផ.ស.ស** ស្មើនឹង **១២៣,១% នៃច្បាប់ហិរញ្ញវត្ថុ**។ ដោយឡែក ក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងឆ្នាំ២០២០ គឺជាឆ្នាំដោយឡែក ដែលចំណូលមិនមែនសារពើពន្ធសម្រេចបានត្រឹមប្រមាណ **២ ០៩៧ ប៊ីលានរៀល(ឬប្រមាណ ៥១៨ លានដុល្លារអាមេរិក)** ត្រូវជា **១,៩២% នៃផ.ស.ស** ទាបជាងច្បាប់ហិរញ្ញវត្ថុ **២៥,៣%** និងបានរួមចំណែកប្រមាណ **៩% នៃចំណូលចរន្តសរុប** ដោយសារវិស័យសេដ្ឋកិច្ចសំខាន់ៗត្រូវទទួលរងផលប៉ះពាល់គួរឱ្យកត់សម្គាល់។

ក្នុងរចនាសម្ព័ន្ធនៃចំណូលថវិកាជាតិ, ចំណូលមិនមែនសារពើពន្ធមានវិសាលភាពធំទូលាយ និងជាប្រភេទចំណូលតាមវិស័យ ដែលទទួលបានពីសកម្មភាពជាច្រើនផ្សេងគ្នា ជាអាទិ៍មាន ចំណូលបានមកពីការចាត់ចែងទ្រព្យសម្បត្តិរដ្ឋ ផលពីសម្បទាន កម្រៃសេវាសាធារណៈ ភាគលាភសហគ្រាសសាធារណៈ ផលពីការពិន័យ និងចំណូលមិនមែនសារពើពន្ធដទៃទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នច្រើន និងរាជធានី-ខេត្ត និងមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាស្ថាប័នតាមដាន ត្រួតពិនិត្យ និងជំរុញការប្រមូលចំណូលតាមរយៈអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ។

ដោយចំណូលមិនមែនសារពើពន្ធជាប្រភេទចំណូលតាមវិស័យ ស្ថិតនៅក្រោមការគ្រប់គ្រង និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័នច្រើនដោយឡែកៗពីគ្នា ធ្វើឱ្យការគ្រប់គ្រង និងកៀរគរប្រមូលចំណូលនេះមានលក្ខណៈស្មុគស្មាញ និងមិនទាន់អស់សក្តានុពល។ ម្យ៉ាងវិញទៀត ដោយបច្ចុប្បន្ននេះ វិធាន នីតិវិធី និងក្របខ័ណ្ឌគតិយុត្តមិនទាន់គ្រប់ជ្រុងជ្រោយ និងពេញលេញ សម្រាប់ធានាឱ្យការប្រមូលចំណូលនេះសក្តិសមនឹងតួនាទីដ៏សំខាន់របស់ខ្លួននៅក្នុងរចនាសម្ព័ន្ធនៃចំណូលថវិកាជាតិ, ដូច្នេះ ចាំបាច់ត្រូវមានក្របខ័ណ្ឌគតិយុត្តមួយច្បាស់លាស់ គ្រប់ជ្រុងជ្រោយ និងពេញលេញ តាមរយៈការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដែលជាកម្មវត្ថុនៃការពិគ្រោះយោបល់ នៃអង្គសិក្ខាសាលានេះ។

សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធដែលបានរៀបចំនេះ គឺជាការធ្វើបច្ចុប្បន្នភាពនៃបទប្បញ្ញត្តិ គោលការណ៍ វិធាន និងនីតិវិធី និងការបំពេញបន្ថែមនូវចំណុចខ្វះខាតមួយចំនួន ដែលដកស្រង់ពីបទពិសោធន៍នៃការអនុវត្តកន្លងមក ក៏ដូចជាបទពិសោធន៍នៃឧត្តមានុវត្តជាអន្តរជាតិ ជាពិសេសពាក់ព័ន្ធនឹងការពង្រឹងសិទ្ធិអំណាច, ការបែងចែកការទទួលខុសត្រូវ, ភាពប្រទាក់ក្រឡាគ្នាពេញលេញរវាងក្រសួង- ស្ថាប័ន រាជធានី-ខេត្ត និងអង្គភាពប្រមូលចំណូល, វិធានការតឹងទារបំណុល, និងការដាក់ពិន័យទោសទណ្ឌ ដើម្បីធានាប្រសិទ្ធភាព និងស័ក្តសិទ្ធិភាព ក្នុងការគ្រប់គ្រង និងការកៀរគរប្រមូលចំណូល។ ស្របតាមយុទ្ធសាស្ត្រកៀរគរចំណូល២០១៩-២០២៣ សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ត្រូវពិនិត្យ និងអនុម័ត ឱ្យបាននៅក្នុងឆ្នាំ២០២២។

ជាទីបញ្ចប់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ជុំ ទិជិត្ត** តាងនាម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** បានថ្លែងកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំទទួលបន្ទុក, ក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ, ក្រុមប្រឹក្សានីតិកម្ម និងអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានខិតខំក្រៅពីបំពេញតួនាទី និងភារកិច្ចស្នូលរបស់ខ្លួន, ក៏បានខិតខំចូលរួមយ៉ាងសកម្មក្នុងការរៀបចំសេចក្តីព្រាងច្បាប់នេះឡើង ដោយមិនបង្អង់ដៃឡើយ និងបានបន្តនីតិវិធីរហូតឈានដល់ការរៀបចំសិក្ខាសាលាពិគ្រោះយោបល់នៅថ្ងៃនេះ តាមប្រព័ន្ធអនឡាញ ទោះបីជាស្ថិតក្នុងបរិការណ៍នៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ដ៏សែនលំបាកនេះ និងជាពិសេសក៏សូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួង- ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការចូលរួមក្នុងអង្គសិក្ខាសាលានេះ។